00850149

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 02/10/2012
ម៉ោង (Time/Heure): 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E236/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

# អនុស្សរណៈ-អង្គជំនុំជម្រះសាលាដំបូង

**សាធារណៈ / Public**

ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រមទាំងអស់, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះ[illegible] និងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ

**កម្មវត្ថុ:** ការបញ្ជាក់ជាបឋមអំពីបុគ្គលដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងអំឡុង សវនាការលើចំណុចអង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង ០០២/០១

១. ក្នុងកិច្ចប្រជុំរៀបចំសវនាការ ឬក្រោយពេលនៃកិច្ចប្រជុំនេះ ភាគីបានចង្អុលបង្ហាញបុគ្គលទាំងឡាយចេញពីក្នុងបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញមុនៗរបស់ខ្លួន ដែលខ្លួនបានស្នើសុំកោះហៅពាក់ព័ន្ធនឹងចំណុចអង្គហេតុដែលត្រូវធ្វើសវនាការទាក់ទិននឹងការផ្លាស់ទីលំនៅប្រជាជនក្នុងសំណុំរឿង ០០២/០១ (ឯកសារ E236)។ ចាប់តាំងពីពេលនោះ អង្គជំនុំជម្រះសាលាដំបូងបានពិនិត្យមើលឡើងវិញទៅលើបុគ្គលចំនួន ៥៣ រូប ដែលភាគីបានស្នើសុំកោះហៅ។ អង្គជំនុំជម្រះយល់ឃើញថាបុគ្គល ដូចខាងក្រោម មានភាពពាក់ព័ន្ធបំផុតទៅនឹងចំណុចអង្គហេតុដែលត្រូវធ្វើសវនាការទាំងនេះ និង ជាបុគ្គលដែលទំនងបំផុតដែលត្រូវផ្តល់សក្ខីកម្មនៅសវនាការតាមលំដាប់លំដោយដែលនឹងត្រូវសម្រេចក្រោយពីមានកិច្ចពិគ្រោះយោបល់ជាមួយអង្គភាពគាំពារសាក្សី និងអ្នកជំនាញ។

i. សាក្សីដែលមានរហស្សនាម TCW-253 (សហព្រះរាជអាជ្ញា, មេធាវីការពារជនជាប់ចោទ នួន ជា)

ii. សាក្សីដែលមានរហស្សនាម TCW-356 (សហព្រះរាជអាជ្ញា, មេធាវីការពារជនជាប់ចោទ ខៀវ សំផន)

iii. សាក្សីដែលមានរហស្សនាម TCW-536 (សហព្រះរាជអាជ្ញា, មេធាវីការពារជនជាប់ចោទ ខៀវ សំផន)

iv. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-25 (សហព្រះរាជអាជ្ញា)*

v. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-45 (សហព្រះរាជអាជ្ញា)*

vi. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-64 (សហព្រះរាជអាជ្ញា)*

vii. សាក្សីដែលមានរហស្សនាម TCW-247 (សហព្រះរាជអាជ្ញា)

viii. សាក្សីដែលមានរហស្សនាម TCW-285 (សហព្រះរាជអាជ្ញា)*

ix. សាក្សីដែលមានរហស្សនាម TCW-362 (សហព្រះរាជអាជ្ញា)*

x. សាក្សីដែលមានរហស្សនាម TCW-661 (សហព្រះរាជអាជ្ញា)*

xi. សាក្សីដែលមានរហស្សនាម TCW-690 (សហព្រះរាជអាជ្ញា)*

xii. សាក្សីដែលមានរហស្សនាម TCW-701 (សហព្រះរាជអាជ្ញា)*

xiii. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-1 (សហព្រះរាជអាជ្ញា, មេធាវីការពារជនជាប់ចោទ នួន ជា)*

xiv. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-169 (សហព្រះរាជអាជ្ញា, សហមេធាវីនាំមុខ)*

xv. សាក្សីដែលមានរហស្សនាម TCW-527 (សហមេធាវីនាំមុខ)

xvi. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-9 (សហមេធាវីនាំមុខ)

xvii. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-35 (សហមេធាវីនាំមុខ)

xviii. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-59 (សហមេធាវីនាំមុខ)

xix. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-82 (សហមេធាវីនាំមុខ)

xx. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-105 (សហមេធាវីនាំមុខ)

xxi. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-108 (សហមេធាវីនាំមុខ)

xxii. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-116 (សហមេធាវីនាំមុខ)

xxiii. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-187 (សហមេធាវីនាំមុខ)

xxiv. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-188 (សហមេធាវីនាំមុខ)

xxv. សាក្សីដែលមានរហស្សនាម TCW-624 (មេធាវីការពារជនជាប់ចោទ នួន ជា)

២. អង្គជំនុំជម្រះយល់ឃើញថាបុគ្គលខាងលើមានឈ្មោះនៅក្នុងបញ្ជីអាទិភាពបុគ្គលដែលត្រូវផ្តល់សក្ខីកម្មទាក់ទិននឹងការផ្លាស់ទីលំនៅប្រជាជន ដែលអង្គជំនុំជម្រះអាចជ្រើសរើសចេញពីបញ្ជីនេះ។ ទោះជាយ៉ាងណាក៏ដោយ គួរបញ្ជាក់ថាការពិនិត្យមើលឡើងវិញអំពីបុគ្គលទាំងនេះកំពុងតែដំណើរការ ហើយម្យ៉ាងវិញទៀត ការបង្ហាញភស្តុតាងនានាក៏កំពុងត្រូវបានធ្វើផងដែរ។ ហេតុដូចនេះ បញ្ជីនេះអាចនឹងត្រូវបានកាត់បន្ថយដោយអង្គជំនុំជម្រះ ប្រសិនបើចាំបាច់ ដើម្បីផលប្រយោជន៍នៃការជំនុំជម្រះដ៏ឆាប់រហ័ស។

៣. អង្គជំនុំជម្រះយល់ឃើញថាសាក្សីបន្ថែមដូចខាងក្រោម ក៏ពាក់ព័ន្ធទៅនឹងចំណុចអង្គហេតុដែលត្រូវធ្វើសវនាការទាំងនេះ និងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីឈ្មោះបម្រុង ដោយរង់ចាំការពិនិត្យមើលឡើងវិញបន្ថែមទៀត៖

i. សាក្សីដែលមានរហស្សនាម TCW-161 (សហព្រះរាជអាជ្ញា, មេធាវីការពារជនជាប់ចោទ នួន ជា)*

ii. សាក្សីដែលមានរហស្សនាម TCW-507 (សហព្រះរាជអាជ្ញា)*

iii. សាក្សីដែលមានរហស្សនាម TCW-674 (សហព្រះរាជអាជ្ញា)

iv. ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-89 (សហព្រះរាជអាជ្ញា)*

v. ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-54 (សហមេធាវីនាំមុខ)

vi. ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-62 (សហមេធាវីនាំមុខ)

vii. ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-117 (សហមេធាវីនាំមុខ)

viii. ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-150 (សហមេធាវីនាំមុខ)

ix. ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-170 (សហមេធាវីនាំមុខ)

x. សាក្សីដែលមានរហស្សនាម TCW-258 (មេធាវីការពារជនជាប់ចោទ នួន ជា)

xi. សាក្សីដែលមានរហស្សនាម TCW-643 (មេធាវីការពារជនជាប់ចោទ នួន ជា)

៤. ប្រសិនបើសហព្រះរាជអាជ្ញា សហមេធាវីនាំមុខ ឬមេធាវីការពារជនជាប់ចោទ នួន ជា យល់ឃើញថាខ្លួនមានបំណងចង់កោះហៅបុគ្គលណាម្នាក់ក្នុងបញ្ជីឈ្មោះបម្រុង ជំនួសឱ្យបុគ្គលណាម្នាក់ដែលខ្លួនបានស្នើសុំស្ដាប់សក្ខីកម្មនៅក្នុងបញ្ជីអាទិភាព ខ្លួនអាចជូនដំណឹងមកមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងអំពីបញ្ហានេះ ដោយផ្ដល់សេចក្ដីពន្យល់គ្រួសៗអំពីមូលហេតុនៃការស្នើសុំបុគ្គលជំនួសនេះ។

៥. បុគ្គលទាំងឡាយដែលមានកំណត់ដោយសញ្ញាផ្កាយ(*)គឺជាបុគ្គលដែលជនជាប់ចោទ អៀង សារី បានលះបង់សិទ្ធិមានវត្តមានក្នុងពេលដែលបុគ្គលទាំងនោះផ្ដល់សក្ខីកម្ម។ ការបញ្ជាក់ពីការលះបង់សិទ្ធិនេះត្រូវបានជូនដំណឹងមកអង្គជំនុំជម្រះមុនពេលចេញអនុស្សរណៈនេះ។ អង្គជំនុំជម្រះសាលាដំបូងសូមអរគុណទុកជាមុន ប្រសិនបើមេធាវីការពារជនជាប់ចោទ រ អៀង សារី អាច បញ្ជាក់មកអង្គជំនុំ-ជម្រះសាលាដំបូងឱ្យបានឆាប់បំផុត ថាតើបុគ្គលណាខ្លះ ប្រសិនបើមានដូចមានរាយនាមក្នុងកថាខណ្ឌ ១ និងកថាខណ្ឌ ៣ ខាងលើត្រូវបានចាត់ទុកថាសមស្របដើម្បីស្ដាប់សក្ខីកម្មនៅចំពោះមុខអង្គជំនុំ-ជម្រះ បន្ទាប់ពីមេធាវីការពារជនជាប់ចោទ អៀង សារី បានចេញលិខិតបោះបង់សិទ្ធិ។

៦. ប្រការនេះនាំឱ្យអង្គជំនុំជម្រះចាត់ទុកថាបុគ្គលចំនួន ១៨ រូប ដូចខាងក្រោម ពុំសូវពាក់ព័ន្ធទៅនឹងចំណុចអង្គហេតុដែលត្រូវធ្វើសវនាការទាំងនេះ និងពុំស្ដាប់សក្ខីកម្មរបស់ពួកគាត់ឡើយ៖ សាក្សីដែលមានរហស្សនាម TCW-458*, TCW-714*, ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម T CCP-138* (សហព្រះរាជអាជ្ញា), សាក្សីដែលមានរហស្សនាម TCW-43* សាក្សីដែលមានរហស្សនាម

TCW-565* (សហព្រះរាជអាជ្ញា និងមេធាវីការពារជនជាប់ចោទ នួន ជា), អ្នកជំនាញដែលមានរហស្សនាម TCE-74, សាក្សីដែលមានរហស្សនាម TCW-62, TCW-92, TCW-139, TCW-204, TCW-213, TCW-223, TCW-230, TCW-342, TCW-497, TCW-509, TCW-539 និង TCW-628 (មេធាវីការពារជនជាប់ចោទ នួន ជា)។